00967055

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception):
24 / 12 / 2013
ម៉ោង (Time/Heure): 13:30
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA



សាធារណៈ / Public

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

# អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១៣

**ជូនចំពោះ:** **ភាគីទាំងអស់ក្នុងសំណុំរឿង០០២**

**ពី:** **ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង**

**ចម្លងជូន:** **លោក/លោកស្រីចៅក្រម និងមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង**

**កម្មវត្ថុ:** **ផែនការការងាររបស់អង្គជំនុំជម្រះសាលាដំបូងសម្រាប់សំណុំរឿង០០២/០២ និងការកំណត់កាលបរិច្ឆេទនៃការដាក់ឯកសារនាពេលខាងមុខ**

## សេចក្តីផ្តើម

1. កាលពីថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០១៣ ប្រធានអង្គជំនុំជម្រះសាលាដំបូង បានចេញអនុស្សរណៈមួយ ដែលបានសម្រេចថា ការតែងតាំងក្រុមប្រឹក្សាជំនុំជម្រះទីពីរនៅក្នុងអង្គជំនុំជម្រះសាលាដំបូងដើម្បីជំនុំ-ជម្រះលើការចោទប្រកាន់នានាដែលនៅសេសសល់ក្នុងសំណុំរឿង ០០២ នោះ នឹងមិនអាចប្រព្រឹត្តទៅបានឆាប់រហ័សជាងកិច្ចដំណើរការនីតិវិធីជាមួយនឹងក្រុមប្រឹក្សាជំនុំជម្រះបច្ចុប្បន្ន ដែលពួកគាត់បានយល់ដឹងអំពីសំណុំរឿងរួចហើយនោះទេ។ នៅក្នុងអនុស្សរណៈនោះ ប្រធានអង្គជំនុំជម្រះបានកត់សម្គាល់ថា អង្គជំនុំជម្រះសាលាដំបូងនឹងចេញផែនការការងារសម្រាប់សំណុំរឿង ០០២/០២ ឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន។ អង្គជំនុំជម្រះសាលាដំបូងបានភ្ជាប់ជាឧបសម្ព័ន្ធនូវផែនការការងាររបស់ខ្លួនទៅនឹងអនុស្សរណៈនេះ។

2. ផែនការការងាររបស់អង្គជំនុំជម្រះសាលាដំបូងសម្រាប់សំណុំរឿង ០០២/០២ គូសបញ្ជាក់អំពីដំណាក់កាលសំខាន់ៗ និងសកម្មភាពចាំបាច់មួយចំនួនមុនពេលចាប់ផ្តើមសវនាការលើអង្គសេចក្តីនៅក្នុងសំណុំរឿង ០០២/០២។ ផែនការការងារនេះ ផ្តល់នូវព័ត៌មានអំពីការកំណត់ពេលវេលានៃដំណាក់កាលនីមួយៗ និងសកម្មភាពការងារមួយចំនួនទៀតដែលនឹងត្រូវសម្រេចដោយអង្គជំនុំជម្រះសាលា-ដំបូង។ ផែនការការងារនេះមិនមានគោលបំណងផ្តល់នូវព័ត៌មានទូលំទូលាយអំពីចំណាត់ការរបស់អង្គជំនុំជម្រះទៅលើគ្រប់ដំណាក់កាលទាំងអស់នៅក្នុងអំឡុងពេលនៃការជំនុំជម្រះនោះទេ ប៉ុន្តែវាមានគោលបំណងផ្តល់នូវការណែនាំជាទូទៅដល់ភាគីនានា និងជាសេចក្តីសង្ខេបពេញលេញមួយសម្រាប់សាធារណជនយល់បានអំពីដំណាក់កាលនីមួយៗនៃកិច្ចដំណើរការនីតិវិធី។

## ព័ត៌មានបន្ថែមអំពីដំណាក់កាលដំបូងនៃផែនការការងាររបស់អង្គជំនុំជម្រះសាលាដំបូង

3. អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ឃើញថា ដំណាក់កាលនីតិវិធីសំខាន់ៗបន្ថែមមួយចំនួន ត្រូវតែយកមកពិចារណា និងត្រូវតែបញ្ចប់ឱ្យបានមុនពេលចាប់ផ្តើមសវនាការដេញដោលលើភ័ស្តុតាង។ នីតិវិធីទាំងនោះរួមមាន ការវាយតម្លៃលើសម្បទារបស់ជនជាប់ចោទ ការដាក់បញ្ជីឈ្មោះសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីដែលពាក់ព័ន្ធ និងដែលស្នើសុំឱ្យមកផ្តល់សក្ខីកម្មនៅពេលសវនាការ ការដាក់បញ្ជីឯកសារពាក់ព័ន្ធ ការសម្រេចអំពីបញ្ហាអញ្ញត្រកម្មសំខាន់ៗ ការបើកកិច្ចប្រជុំត្រៀមរៀបចំសវនាការបន្ថែមទៀត និងការសម្រេចលើសំណើសុំផ្សេងៗដែលដាក់ដោយភាគីនានា។ ទោះបីជាមានការទទួលស្គាល់ថា វិសាលភាពនៃការជំនុំជម្រះត្រូវតែសម្រេចជាមុនក៏ដោយ ក៏សហ-ព្រះរាជអាជ្ញាមិនបានគូសបញ្ជាក់ពីពេលវេលាសម្រាប់ការពិចារណាលើវិសាលភាពនេះនៅក្នុងការគិតគូរអំពីកាលបរិច្ឆេទកំណត់នៃការចាប់ផ្តើមសវនាការនៅក្នុងសំណើសុំរបស់ខ្លួននោះទេ។ ដំណាក់កាលនេះ នឹងតម្រូវឱ្យមានពេលវេលាសម្រាប់ការធ្វើសវនាការដេញដោលលើបញ្ហាផ្សេងៗ និងរួមទាំងការចេញសេចក្តីសម្រេចស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីផងដែរ។ ដំណាក់កាលនានាដែលបានគូសបញ្ជាក់ខាងក្រោម និងនៅក្នុងផែនការការងារ នឹងត្រូវយកមកពិចារណារាល់បញ្ហាទាំងអស់ដែលនឹងត្រូវតែពិនិត្យវាយតម្លៃឱ្យបានមុនពេលដែលអង្គជំនុំជម្រះកំណត់អំពីកាលបរិច្ឆេទនៃការចាប់ផ្តើមធ្វើសវនាការដេញដោលលើភ័ស្តុតាង។

4. ព័ត៌មានលម្អិតខាងក្រោម លើកឡើងអំពីបញ្ហាបឋមដែលនឹងកើតឡើងនៅក្នុងដំណាក់កាលដំបូងៗនៃកិច្ចដំណើរការនីតិវិធីសំណុំរឿង ០០២/០២។

5. *ការកំណត់អំពីវិសាលភាពនៃសំណុំរឿង ០០២/០២៖* ភាគីនានាអាចដាក់សារណាជាលាយលក្ខណ៍អក្សរអំពីវិសាលភាពនៃសំណុំរឿង ០០២/០២ ត្រឹមថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១៤។ ចម្លើយតបជាលាយលក្ខណ៍អក្សរទៅនឹងសារណានេះ នឹងមិនទទួលយកនោះទេ។ អង្គជំនុំជម្រះនឹងស្ដាប់ទឡ្ហីករណ៍ផ្ទាល់មាត់អំពីវិសាលភាពនៃការជំនុំជម្រះនៅថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៤។ ទឡ្ហីករណ៍ផ្ទាល់មាត់ទាំងនេះ គួរផ្ដោតតែទៅលើការឆ្លើយតបទៅនឹងសារណាដែលបានដាក់ជាលាយលក្ខណ៍អក្សរប៉ុណ្ណោះ។

6. *ការវាយតម្លៃអំពីសម្បទារបស់ជនជាប់ចោទ៖* មេធាវីការពារក្ដីនឹងត្រូវបានអញ្ជើញឱ្យដាក់សារណាជាលាយលក្ខណ៍អក្សរខ្លីមួយត្រឹមថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១៤ ដោយចង្អុលបង្ហាញថាតើមេធាវីការពារក្ដីយល់ឃើញថា ស្ថានភាពសុខភាពរបស់កូនក្ដីខ្លួនមានការផ្លាស់ប្ដូរដែរ ឬយ៉ាងណា ហើយថាតើមានភាពចាំបាច់ដែរ ឬទេ ក្នុងការវាយតម្លៃឡើងវិញអំពីសម្បទាក្នុងការចូលរួមសវនាការរបស់ពួកគាត់ និង/ឬសមត្ថភាពផ្នែករូបរាងកាយរបស់គាត់ក្នុងការចូលរួមទៅតាមកាលបរិច្ឆេទនៃការជំនុំជម្រះទាំងអស់ដែលបានគ្រោងទុក។

7. *សារណារបស់ក្រុមមេធាវីការពារក្ដី ខៀវ សំផន អំពីការចាប់ផ្ដើមសំណុំរឿង ០០២/០២៖* ក្នុងអំឡុងកិច្ចប្រជុំរៀបចំសវនាការសម្រាប់សំណុំរឿង០០២/០២ ក្រុមមេធាវីការពារក្ដី ខៀវ សំផន បានលើកឡើងជាថ្មីអំពីទស្សនៈរបស់ខ្លួនដែលថា សំណុំរឿង០០២/០១ គួរតែត្រូវបានសម្រេចជាស្ថាពរសិន ដែលរួមទាំងដំណើរការនីតិវិធីប្ដឹងសាទុក្ខ ប្រសិនបើមាន មុនពេលចាប់ផ្ដើមសវនាការដេញដោលលើភ័ស្ដុតាងនៅក្នុងសំណុំរឿង០០២/០២។ ក្រុមមេធាវីការពារក្ដី ខៀវ សំផន អាចដាក់សារណាជាលាយលក្ខណ៍អក្សរលើបញ្ហានេះ ត្រឹមថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០១៤។ អង្គជំនុំជម្រះនឹងស្ដាប់ទឡ្ហីករណ៍ផ្ទាល់មាត់របស់ភាគីផ្សេងទៀត នៅថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៤ ដែលគួរផ្ដោតតែទៅលើការឆ្លើយតបទៅនឹងសារណាដែលបានដាក់ជាលាយលក្ខណ៍អក្សរប៉ុណ្ណោះ។

**ដំណាក់កាលពាក់ព័ន្ធផ្សេងៗទៀតនៃផែនការការងារ**

8. បន្ទាប់មកទៀត អង្គជំនុំជម្រះនឹងកំណត់កាលបរិច្ឆេទដូចខាងក្រោមនេះ៖

(ក) ផ្តល់ឱកាសឲ្យភាគីនានាដើម្បីដាក់សារណាជាលាយលក្ខណ៍អក្សរ ឬធ្វើសេចក្តីសន្និដ្ឋានផ្ទាល់មាត់អំពីអង្គហេតុ/បទចោទនានា ដែលមិនត្រូវបានដាក់បញ្ចូលនៅក្នុងសំណុំរឿង០០២/០២។

(ខ) ផ្តល់ឱកាសឲ្យភាគីពិភាក្សាអំពីអញ្ញត្រកម្មណាមួយ ដែលមិនមែនជាកម្មវត្ថុនៃការធ្វើសវនាការដេញដោល និងដែលមិនទាន់ត្រូវបានសម្រេចរហូតមកទល់ពេលនេះ។

(គ) ការដាក់បញ្ជីឈ្មោះសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញដែលភាគីទាំងអស់ស្នើសុំឲ្យស្តាប់សក្ខីកម្មនៅពេលសវនាការ។ និង

(ឃ) សវនាការបឋម

9. កាលបរិច្ឆេទនៃកិច្ចប្រជុំរៀបចំសវនាការបន្ថែមទៀត នឹងត្រូវកំណត់នៅពេលខាងមុខ ដើម្បីដោះស្រាយបញ្ហាផ្សេងៗដែលនៅសេសសល់មុនពេលចាប់ផ្តើមការជំនុំជម្រះ ប្រសិនបើចាំបាច់។

10. អង្គជំនុំជម្រះសាលាដំបូងបានណែនាំទៅភាគីនានាថា ប្រធានអង្គជំនុំជម្រះបានបង្គាប់ឲ្យការិយាល័យរដ្ឋបាលផ្តល់អាទិភាពលើការបកប្រែសាលក្រមសំណុំរឿង ០០២/០១ ហេតុដូច្នេះ ដើម្បីសម្រួលដល់បញ្ហានេះ អង្គជំនុំជម្រះនឹងសម្របសម្រួលនូវពេលវេលាសម្រាប់ឲ្យភាគីដាក់សារណាជាលាយលក្ខណ៍អក្សររបស់ខ្លួន ចាប់ពីពេលបច្ចុប្បន្ននេះរហូតដល់ពេលចេញសាលក្រមសំណុំរឿង ០០២/០១។

11. ដើម្បីកំណត់កាលបរិច្ឆេទសម្រាប់នីតិវិធីមុនពេលជំនុំជម្រះឲ្យបានឆាប់រហ័ស អង្គជំនុំជម្រះអាចស្នើឲ្យភាគីដាក់នូវសារណាជាលាយលក្ខណ៍អក្សរ ឬកំណត់កាលបរិច្ឆេទសវនាការ និងផ្តល់ការណែនាំឲ្យបានគ្រប់ជ្រុងជ្រោយដល់ភាគីជាមុន អំពីការកំណត់កាលបរិច្ឆេទនានាដើម្បីឲ្យភាគីមានពេលវេលាគ្រប់គ្រាន់សម្រាប់ការត្រៀមរៀបចំ។